**រដ្ឋសភា**

**បណ្ឌិតរដ្ឋ ចាម យៀប**

សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា
តំណាងរាស្ត្រមណ្ឌល ព្រៃវែង
សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ នៃរដ្ឋសភា
ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
ប្រធានក្រុមជាតិ AIPA កម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦

**លិខិតកោតសរសើរ**

**<u>គោរពជូន</u>**

**ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី ជាទីស្រឡាញ់** !

ខ្ញុំបានសង្កេតឃើញថា ក្រោមការដឹកនាំរបស់ **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានបំពេញការងារដឹកនាំ និងការគ្រប់គ្រងថវិកាជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបានបន្តខិតខំរក្សាកំណើនសេដ្ឋកិច្ចឲ្យបានប្រមាណ៧%ក្នុងមួយឆ្នាំ ធ្វើឲ្យស្ថានភាពសេដ្ឋកិច្ចកម្ពុជាបន្តមានសភាពល្អ និងអាចរក្សាបានចីរភាពកំណើន តាមរយៈការខិតខំរកសក្តានុពលប្រភពចំណូលបំពេញរាល់ការចំណាយ ដែលជាសមត្ថកិច្ចដ៏សំខាន់របស់អង្គភាពពីរគឺ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ។

ខ្ញុំសូមកោតសរសើរយ៉ាងស្មោះដល់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយ **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** ក៏ដូចជាថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដឹកនាំដោយឯកឧត្តមបណ្ឌិត **គុណ ញឹម** អគ្គនាយក និងថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំដោយឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ដែលបានខិតខំបំពេញការងារបានយ៉ាងល្អប្រសើរ និងបានយកចិត្តទុកដាក់អនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ ស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពក្នុងការប្រមូលចំណូលទាំងក្នុងផ្នែកគយ និងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ ដើម្បីបំពេញរាល់ការចំណាយបានទាន់ពេលវេលា ជាពិសេសការបន្តអាទិភាពបង្កើនប្រាក់បៀវត្សដល់មន្ត្រីរាជការស៊ីវិល

និងកងកម្លាំងប្រដាប់អាវុធ ឆ្ពោះទៅសម្រេចបានគោលដៅជាង១លានរៀលនៅឆ្នាំ២០១៨ ជាដើម។ល។ និងការបង្កើនការសន្សំសំចៃថវិកាខ្ពស់សម្រាប់ទប់ទល់នូវព្រឹត្តិការណ៍ជាយថាហេតុ ដូចជា ការរងគ្រោះធម្មជាតិ វិបត្តិនយោបាយ។ល។

សមិទ្ធផលខាងលើនេះពិតជាកើតចេញពីកិច្ចសហការ ការសាមគ្គីភាព ពីថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានអង្គភាពសេនាធិការដ៏ល្អពីរ ជាអង្គភាពប្រមូលប្រភពធនធានហិរញ្ញវត្ថុ គឺអគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ។

ក្រៅពីនេះ យើងក៏សូមកោតសរសើរចំពោះមន្ត្រីរាជការនៅគ្រប់អង្គភាព ក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានអនុវត្តបំពេញភារកិច្ចបានយ៉ាងល្អប្រសើរ កន្លងមក។

ជាថ្មីម្តងទៀត ខ្ញុំសូមកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ និង ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកពន្ធដារ ដែលឯកឧត្តមទាំងបីបានយកអស់កម្លាំងកាយចិត្ត ដើម្បីផលប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា ដើម្បីឈានទៅសម្រេច និងបំបាត់ភាពក្រីក្រក្នុងអត្រា១% ក្នុងរៀងរាល់ឆ្នាំ។

សូម **ឯកឧត្តមបណ្ឌិត ទេសរដ្ឋមន្ត្រី** ទទួលនូវការស្រឡាញ់រាប់អានពីខ្ញុំ។

**ប្រធានគណៈកម្មការទី២ នៃរដ្ឋសភា**

បណ្ឌិតរដ្ឋ ជាម យៀប

<u>ចម្លងជូន៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករ
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ-កាលប្បវត្តិ